# 02 한글 익히기 II

ការរៀនហាន់ហ្គឺល(អក្សរកូរ៉េ)២

## 4 자음 1 ព្យញ្ជនៈ ១

K-4

ចំពោះព្យញ្ជនៈកូរ៉េ គឺមានទាំងអស់១៩តួ។ ព្យញ្ជនៈ គឺត្រូវបានង្កើតឡើងទៅតាមរយៈរូបរាងនៃសរីរាង្គដែលធ្វើការបញ្ចេញសម្លេង។ ‘ㄱ’ គឺបង្កើតឡើងទៅតាមរូបរាងចុងអណ្តាតដែលបាំងបំពង់ក ហើយចំណែកឯ‘ㄴ’ គឺបង្កើតទៅតាមរូបរាងអណ្តាតពេលដែលប៉ះនឹងធ្មេញខាងលើ។ រីឯ‘ㅁ’ គឺបង្កើតទៅតាមរូបរាងនៃបបូរមាត់ និង ‘ㅅ’ គឺបង្កើតទៅតាមរូបរាងនៃធ្មេញ ហើយនិង‘ㅇ’វិញ គឺបង្កើតដោយផ្អែកទៅតាមរូបរាងបំពង់កដែលមាននាទីបញ្ចេញសម្លេង។





បើអញ្ចឹង តោះ! យើងសាកល្បងសរសេរជាមួយគ្នា។
សូមស្តាប់ CDបណ្តើរ ហើយចូរថាទៅតាមលំដាប់លំដោយបណ្តើរ។

| 자음 1 ព្យញ្ជនៈ ១ | | | | |
|---|---|---|---|---|
| ㄱ [k/g] | ㄴ [n] | ㄷ [t/d] | ㄹ [r/l] | ㅁ [m] |
| ㅂ [p/b] | ㅅ [s/ʃ] | ㅇ [ŋ] | ㅈ [ʧ/ʤ] | ㅎ [h] |



តើអ្នកបានថាតាមរួចរាល់ហើយមែនទេ? ម្តងនេះ សូមសាកល្បងស្តាប់ម្តងទៀត ហើយសរសេរព្យញ្ជនៈ។

| ព្យញ្ជនៈ | លំដាប់នៃការសរសេរ | ការសរសេរ | | | | | |
|---|---|---|---|---|---|---|---|
| ㄱ [k/g] |  | | | | | | |
| ㄴ [n] |  | | | | | | |
| ㄷ [t/d] |  | | | | | | |
| ㄹ [r/l] |  | | | | | | |
| ㅁ [m] |  | | | | | | |
| ㅂ [p/b] |  | | | | | | |
| ㅅ [s/ʃ] |  | | | | | | |
| ㅇ [ŋ] |  | | | | | | |
| ㅈ [ʧ/ʤ] |  | | | | | | |
| ㅎ [h] |  | | | | | | |



តើសរសេររួចរាល់ហើយមែនទេ? ម្តងនេះ សូមស្តាប់ព្យញ្ជនៈម្តងទៀត ហើយថាតាម។

ចំពោះ 'ㅇ' ពេលវានៅជាព្យញ្ជនៈទីមួយ គឺវាមិនមានសម្លេងនោះទេ តែនៅពេលវានៅជាព្យញ្ជនៈចុងក្រោយគេ វាមានសម្លេង[ŋ]។ ចំពោះព្យញ្ជនៈក្នុងភាសាកូរ៉េ គឺដាច់ខាតត្រូវតែសរសេរជាមួយនឹងស្រៈ។ នៅពេលសរសេរព្យញ្ជនៈបូកជាមួយនឹងស្រៈបញ្ឈរ គឺវាស្ថិតនៅខាងឆ្វេង ហើយនៅពេលសរសេរជាមួយនឹងស្រៈផ្តេកវាត្រូវបានគេសរសេរនៅពីលើ។

| ㄴ | ㅏ |
|---|---|

| ㄴ |
|---|
| ㅗ |



បើអញ្ចឹង តោះ! យើងនាំគ្នាស្តាប់ ហើយសាកល្បងថាតាមបណ្តើរ សរសេរព្យញ្ជនៈនិងស្រៈជាមួយគ្នាបណ្តើរ។

| | | | | | |
|---|---|---|---|---|---|
| (1) | ㄱ | + | ㅏ | → | 가 |
| (2) | ㄴ | | | → | |
| (3) | ㄷ | | | → | |
| (4) | ㄹ | | | → | |
| (5) | ㅁ | | | → | |

| | | | | | |
|---|---|---|---|---|---|
| (6) | ㅂ | + | ㅗ | → | 보 |
| (7) | ㅅ | | | → | |
| (8) | ㅇ | | | → | |
| (9) | ㅈ | | | → | |
| (10) | ㅎ | | | → | |



ម្តងនេះ សូមសាកល្បងសរសេរព្យញ្ជនៈនិងស្រៈភ្ជាប់ជាមួយគ្នា។ ព្យញ្ជនៈ គឺត្រូវបានសរសេរនៅខាងឆ្វេងស្រៈបញ្ឈរ ហើយនិងនៅពីលើស្រៈផ្តេក។ សូមមើលឲ្យបានច្បាស់ ហើយសរសេរ។

| ស្រៈ / ព្យញ្ជនៈ | ㅏ | ㅑ | ㅓ | ㅕ | ㅗ | ㅛ | ㅜ | ㅠ | ㅡ | ㅣ |
|---|---|---|---|---|---|---|---|---|---|---|
| ㄱ | 가 | | | | 고 | | | | | |
| ㄴ | | 냐 | | | | | | | | |
| ㄷ | | | 더 | | | | | | | |
| ㄹ | | | | 려 | | | | | | |
| ㅁ | | | | | 모 | | | | | |
| ㅂ | | | | | | | | | | |
| ㅅ | | | | | | | | | | |
| ㅇ | | | | | | | | | | |
| ㅈ | | | | | | | | | | |
| ㅎ | | | | | | | | | | |



តោះ! យើងមកស្តាប់ ហើយសាកល្បងថាតាមទាំងអស់គ្នាតើល្អដែរឬទេ? សូមសាកល្បងបញ្ចេញសម្លេងអក្សរដែលមានស្រៈនិងព្យញ្ជនៈផ្សំជាមួយគ្នា។ ជាដំបូង សូមសាកល្បងអានជួរដេក។ រួចហើយ សូមអានជួរឈរ។

가　　고

ចំពោះ ‘ㄱ’ នៅពេលដែលសរសេរជាមួយនឹងស្រៈបញ្ឈរ រូបរាងតួអក្សរគឺខុសពីពេលសរសេរជាមួយនឹងស្រៈផ្តេក។ សូមសរសេរដោយប្រុងប្រយ័ត្ន។

## 연습 ការអនុវត្ត

1. សូមសាកល្បងធ្វើការបញ្ចេញសម្លេងព្យញ្ជនៈខាងក្រោមម្តងមួយៗ។ រួចរាល់ហើយឬនៅ? បើអញ្ចឹង សូមធ្វើការស្តាប់ CD ហើយធ្វើការគូសសញ្ញា 'O' ចំពោះចម្លើយដែលត្រូវទៅនឹងការបញ្ចេញសម្លេង។ ចូរប្រុងប្រយ័ត្នការបញ្ចេញសម្លេងដែលខុស ហើយសាកល្បងស្តាប់និងថាតាមម្តងទៀត។

(1) 가 다 마 사　(2) 바 나 라 자　(3) 후 주 수 부　(4) 로 도 노 고
(5) 너 러 저 허　(6) 규 류 슈 쥬　(7) 드 므 브 스　(8) 기 리 지 히

2. សូមស្តាប់ ហើយជ្រើសរើសចម្លើយដែលត្រឹមត្រូវ។

(1) 노래 모래　(2) 가수 다수　(3) 사요 자요
(4) 고리 도리　(5) 머리 허리　(6) 비누 부누

3. សូមស្តាប់ពាក្យខាងក្រោម ហើយថាតាម។

(1) 가수
តារាចម្រៀង



(2) 아기
កូនក្មេង(កូនង៉ែត)



(3) 네모
ការេ



(4) 다리
ស្មាន



(5) 소리
សម្លេង



(6) 모자
មួក



(7) 아버지
លោកឪពុក



(8) 사자
សត្វតោ



(9) 새우
បង្គា



4. ម្ដងនេះ សូមស្ដាប់ ហើយសាកល្បងសរសេរ។

(1)

(2)

(3)

(4)

(5)

(6)



តើសរសេររួចរាល់ហើយមែនទេ? សូមសាកល្បងស្ដាប់ម្ដងទៀត។



ម្ដងនេះ សូមស្ដាប់ ហើយសាកល្បងថាតាម។ សូមសាកល្បងធ្វើដដែលៗឲ្យបាន៣ដង។

정답
1. (1) 마 (2) 자 (3) 부 (4) 도 (5) 너 (6) 류 (7) 스 (8) 히
2. (1) 노래 (2) 가수 (3) 자요 (4) 고리 (5) 허리 (6) 비누
4. (1) 고기 (2) 나무 (3) 도로 (4) 모자 (5) 버스 (6) 바지

## 5 자음 2 ព្យញ្ជនៈ ២

K-5

‘ㅋ, ㅌ, ㅍ, ㅊ’ គឺបង្កើតឡើងដោយការបន្ថែមគំនូសមួយឆ្នូតពីលើ ‘ㄱ, ㄷ, ㅂ, ㅈ’។ ដូច្នេះហើយ សម្លេងរបស់‘ㅋ, ㅌ, ㅍ, ㅊ’ គឺខ្លាំងជាងនិងផ្ទុកខ្យល់ច្រើនជាង‘ㄱ, ㄷ, ㅂ, ㅈ’។ យើងត្រូវបញ្ចេញខ្យល់ពីក្នុងមាត់ឲ្យបានខ្លាំង ដើម្បីធ្វើការបញ្ចេញសម្លេង។ សូមស្តាប់ CDបណ្តើរ ហើយថាតាមលំដាប់លំដោយបណ្តើរ។

| | | |
|---|---|---|
| ㄱ [k/g] | → | ㅋ [kʰ] |
| ㄷ [t/d] | | ㅌ [tʰ] |
| ㅂ [p/b] | | ㅍ [pʰ] |
| ㅈ [ʧ/ʤ] | | ㅊ [ʧʰ] |



តោះ! យើងសាកល្បងអនុវត្តម្តងទៀតជាមួយគ្នា។

(1) សូមអានឆ្លាស់ ‘ㄱ’ និង ‘ㅋ’ ទៅវិញទៅមក។

(2) សូមអានឆ្លាស់ ‘ㄷ’ និង ‘ㅌ’ ទៅវិញទៅមក។

(3) សូមអានឆ្លាស់ ‘ㅂ’ និង ‘ㅍ’ ទៅវិញទៅមក។

(4) សូមអានឆ្លាស់ ‘ㅈ’ និង ‘ㅊ’ ទៅវិញទៅមក។



តើអ្នកមានអារម្មណ៍ដឹងពីភាពខុសគ្នានៃការបញ្ចេញខ្យល់ហើយមែនដែរឬទេ?



អញ្ចឹង ម្តងនេះសូមស្តាប់ម្តងទៀត ហើយសាកសរសេរព្យញ្ជនៈ។

| ព្យញ្ជនៈ | លំដាប់នៃការសរសេរ | ការសរសេរ | | | | | |
|---|---|---|---|---|---|---|---|
| ㅋ [kʰ] | ①②ㅋ | | | | | | |
| ㅌ [tʰ] | ①②③ㅌ | | | | | | |
| ㅍ [pʰ] | ①②③④ㅍ | | | | | | |
| ㅊ [ʧʰ] | ①②③ㅊ | | | | | | |



តើសរសេររួចរាល់ហើយមែនទេ? ម្តងនេះ សូមស្តាប់ព្យញ្ជនៈម្តងទៀត ហើយថាតាម។ អញ្ចឹង យើងសាកល្បងផ្សំព្យញ្ជនៈសម្លេងខ្លាំង និងស្រៈបញ្ចូលគ្នា។



ម្តងនេះយើងស្តាប់បណ្តើរ ហើយសរសេរព្យញ្ជនៈនិងស្រៈផ្សំចូលគ្នាបណ្តើរ តើល្អដែរឬទេ?
ចូរសាកល្បងសរសេរស្រៈផ្សំចូលគ្នា។

| | | | | | |
|---|---|---|---|---|---|
| (1) | ㅋ | + ㅏ | → | 카 |
| (2) | ㅌ | + ㅏ | → | |
| (3) | ㅍ | + ㅏ | → | |
| (4) | ㅊ | + ㅏ | → | |

| | | | | |
|---|---|---|---|---|
| (5) | ㅋ | + ㅗ | → | 코 |
| (6) | ㅌ | + ㅗ | → | |
| (7) | ㅍ | + ㅗ | → | |
| (8) | ㅊ | + ㅗ | → | |



យើងបាននិយាយរួចហើយថា ព្យញ្ជនៈគឺត្រូវបានសរសេរនៅខាងឆ្វេងស្រៈបញ្ឈរហើយនិងនៅពីលើស្រៈផ្ដេក មែនទេ? បើអញ្ចឹង សូមមើលដោយយកចិត្តទុកដាក់ ហើយចូរសាកល្បងសរសេរ។

| ស្រៈ / ព្យញ្ជនៈ | ㅏ | ㅓ | ㅗ | ㅜ | ㅡ | ㅣ | ㅐ | ㅔ |
|---|---|---|---|---|---|---|---|---|
| ㅋ | 카 | | 코 | | | 키 | | |
| ㅌ | | 터 | | | | | 태 | |
| ㅍ | | | 포 | | | 피 | | |
| ㅊ | | | | 추 | | | | |



តើអ្នកបានសរសេររួចរាល់ហើយមែនដែរឬទេ? សូមស្ដាប់ម្ដងទៀត ហើយថាតាម។
ជាដំបូង សូមសាកល្បងអានជួរដេក ហើយបន្ទាប់មកចូរអានជួរឈរ។

## 연습 ការអនុវត្ត

1. សូមសាកល្បងធ្វើការបញ្ចេញសម្លេងស្រៈខាងក្រោមម្ដងមួយៗ។ តើអ្នកបានធ្វើការបញ្ចេញសម្លេងរួចរាល់ហើយមែនដែរឬទេ? បើអញ្ចឹង សូមធ្វើការស្ដាប់ CD ហើយចូរគូសសញ្ញា 'O' ចំពោះចម្លើយដែលត្រឹមត្រូវទៅនឹងការបញ្ចេញសម្លេង។ ចូរប្រុងប្រយ័ត្នចំពោះការបញ្ចេញសម្លេងដែលខុស ហើយសាកល្បងស្ដាប់និងថាតាមម្ដងទៀត ។

(1) 차 카 타 파 (2) 초 코 토 포 (3) 쿠 투 푸 추 (4) 티 치 키 피

2. ចូរប្រុងប្រយ័ត្នការបញ្ចេញសម្លេងដែលខុស ហើយសាកល្បងស្ដាប់ម្ដងទៀត និងថាតាម។
សូមស្ដាប់ ហើយជ្រើសរើសចម្លើយដែលត្រឹមត្រូវ។

(1) 보도 포도 (2) 기자 기차 (3) 고 코
(4) 타요 다요 (5) 치마 지마 (6) 스키 수키

3. សូមស្តាប់ពាក្យខាងក្រោម ហើយថាតាម។

(1) 치마
សំពត់



(2) 코
ច្រមុះ



(3) 타조
សត្វអូទ្រីស



(4) 포도
ផ្លែទំពាំងបាយជូ



(5) 카메라
ម៉ាស៊ីនថតរូប



(6) 스키
ស្គី



(7) 커피
កាហ្វេ



(8) 기차
រថភ្លើង



(9) 피아노
ព្យាណូ



4. ម្តងនេះសូមស្តាប់ ហើយសាកល្បងសរសេរ។

(1)

(2)

(3)

(4)

(5)

(6)



តើសរសេររួចរាល់ហើយមែនទេ? សូមសាកល្បងស្តាប់ម្តងទៀត។



ម្តងនេះ សូមស្តាប់ ហើយសាកល្បងថាតាម។ សូមសាកល្បងធ្វើដដែលៗឲ្យបានពាដង។

정답
1. (1) 차 (2) 코 (3) 푸 (4) 티
2. (1) 포도 (2) 기차 (3) 코 (4) 타요 (5) 치마 (6) 스키
4. (1) 치즈 (2) 커피 (3) 기타 (4) 포크 (5) 고추 (6) 쿠키

## 6 자음 3 ព្យញ្ជនៈ ៣

K-6

‘ㄲ, ㄸ, ㅃ, ㅆ, ㅉ’គឺត្រូវបានបង្កើតឡើងដោយការបន្ថែមតួអក្សរមួយត្រួតពីលើ ‘ㄱ, ㄷ, ㅂ, ㅅ, ㅈ’។ ចំពោះសម្លេងរបស់ ‘ㄲ, ㄸ, ㅃ, ㅆ, ㅉ’ គឺត្រូវតែបញ្ចេញសម្លេងដោយសង្កត់នៅបំពង់ក។



សូមស្ដាប់CDបណ្ដើរ ថាតាមលំដាប់លំដោយបណ្ដើរ។

| | | |
|---|---|---|
| ㄱ [k/g] | | ㄲ [k'] |
| ㄷ [t/d] | | ㄸ [t'] |
| ㅂ [p/b] | → | ㅃ [p'] |
| ㅅ [s] | | ㅆ [s'] |
| ㅈ [ʧ/ʤ] | | ㅉ [ʧ'] |

តើអ្នកបានស្ដាប់និងថាតាមរួចរាល់ហើយមែនទេ? បើអញ្ចឹង សូមសាកល្បងធ្វើការវែកញែក ហើយធ្វើការបញ្ចេញសម្លេងព្យញ្ជនៈដើម(ㄱ, ㄷ, ㅂ, ㅅ, ㅈ) ព្យញ្ជនៈខ្លាំង(ㅋ, ㅌ, ㅍ, ㅊ) និង ព្យញ្ជនៈភ្លោះ(ㄲ, ㄸ, ㅃ, ㅆ, ㅉ)។ ចំពោះ 'ㄲ, ㄸ, ㅃ, ㅆ, ㅉ' ត្រូវបន្ថែមកម្លាំងហើយធ្វើការបញ្ចេញសម្លេង។



នៅពេលដែលធ្វើការបញ្ចេញសម្លេងព្យញ្ជនៈនីមួយៗ សូមដាក់ដៃបាំងមាត់ ហើយសាកល្បងស្វែងយល់ពីកម្លាំងខ្យល់។

(1) សូមថាទៅតាមលំដាប់លំដោយ ‘ㅋ’ និង ‘ㄱ’, ‘ㄲ’។

(2) សូមថាទៅតាមលំដាប់លំដោយ ‘ㅌ’ និង ‘ㄷ’, ‘ㄸ’។

(3) សូមថាទៅតាមលំដាប់លំដោយ ‘ㅍ’ និង ‘ㅂ’, ‘ㅃ’ ។

(4) សូមថាទៅតាមលំដាប់លំដោយ ‘ㅅ’ និង ‘ㅆ’។

(5) សូមថាទៅតាមលំដាប់លំដោយ ‘ㅊ’ និង ‘ㅈ’, ‘ㅉ’។



បើអញ្ចឹង ពេលនេះសូមស្តាប់ម្តងទៀតបណ្តើរ សរសេរព្យញ្ជនៈបណ្តើរ។

| ព្យញ្ជនៈ | លំដាប់នៃការសរសេរ | ការសរសេរ | | | | | |
|---|---|---|---|---|---|---|---|
| ㄲ [k΄] |  | | | | | | |
| ㄸ [t΄] |  | | | | | | |
| ㅃ [p΄] |  | | | | | | |
| ㅆ [s΄] |  | | | | | | |
| ㅉ [ʧ΄] |  | | | | | | |



តើសរសេររួចរាល់អស់ហើយមែនទេ? ម្តងនេះ សូមសាកល្បងស្តាប់ព្យញ្ជនៈម្តងទៀត ហើយថាតាម។



បើអញ្ចឹង យើងស្តាប់ហើយថាតាមបណ្តើរ សរសេរព្យញ្ជនៈនិងស្រៈជាមួយគ្នាបណ្តើរ។

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| (1) | ㄲ | | | → | 까 | | (6) | ㄲ | | | → | 꼬 |
| (2) | ㄸ | | | → | | | (7) | ㄸ | | | → | |
| (3) | ㅃ | + | ㅏ | → | | | (8) | ㅃ | + | ㅗ | → | |
| (4) | ㅆ | | | → | | | (9) | ㅆ | | | → | |
| (5) | ㅉ | | | → | | | (10) | ㅉ | | | → | |



ម្តងនេះ សូមសាកល្បងសរសេរស្រៈលាយបញ្ចូលគ្នាជាមួយព្យញ្ជនៈ។

| ស្រៈ / ព្យញ្ជនៈ | ㅏ | ㅓ | ㅗ | ㅜ | ㅡ | ㅣ | ㅐ | ㅔ |
|---|---|---|---|---|---|---|---|---|
| ㄲ | 까 | | | | | | | 께 |
| ㄸ | | 떠 | | | | | 때 | |
| ㅃ | | | 뽀 | | | 삐 | | |
| ㅆ | | 써 | | | 쓰 | | | |
| ㅉ | | | | 쭈 | | | 째 | |



រួចរាល់ហើយមែនទេ? សូមសាកល្បងស្តាប់ម្តងទៀត ហើយចូរថាតាម។
ជាដំបូង សូមសាកល្បងអានជួរដេក។



តើបានស្តាប់លឺហើយមែនទេ? ម្តងនេះ សូមសាកល្បងអានជួរឈរ។

## 연습 ការអនុវត្ត

1. សូមសាកល្បងបញ្ចេញសម្លេងនូវតួអក្សរខាងក្រោមម្តងមួយៗ។ តើអ្នកបានធ្វើការបញ្ចេញសម្លេងរួចរាល់ហើយមែនដែរឬទេ? បើអញ្ចឹង សូមធ្វើការស្តាប់ CD បន្ទាប់មកចូរគូសសញ្ញា 'O' ចំពោះចម្លើយដែលត្រឹមត្រូវទៅនឹងការបញ្ចេញសម្លេង។ចូរប្រុងប្រយ័ត្នចំពោះការបញ្ចេញសម្លេងដែលខុស ហើយសាកល្បងស្តាប់និងថាតាមម្តងទៀត។

   (1) 까 따 빠 싸 짜　(2) 꼬 또 뽀 쏘 쪼　(3) 꾸 뚜 뿌 쑤 쭈　(4) 끼 띠 삐 씨 찌

2. សូមស្តាប់ ហើយជ្រើសរើសចម្លើយដែលត្រឹមត្រូវ។

   (1) 가요　까요　(2) 차요　짜요　(3) 커요　꺼요
   (4) 사요　싸요　(5) 부리　뿌리　(6) 아파요　바빠요

3. សូមស្តាប់ពាក្យខាងក្រោម ហើយថាតាម។

(1) 까치
សត្វពពេច


(2) 어깨
ស្មា


(3) 귀뚜라미
សត្វចង្រិត


(4) 뿌리
ឬស


(5) 아저씨
ពូ


(6) 찌개
សម្ល


4. ម្តងនេះ សូមសាកល្បងស្តាប់ ហើយសរសេរ។

(1)

| | |
|---|---|
| | |

(2)

| | |
|---|---|
| | |

(3)

| | |
|---|---|
| | |

(4)

| | |
|---|---|
| | |

(5)

| | |
|---|---|
| | |

(6)

| | |
|---|---|
| | |



តើអ្នកសរសេររួចរាល់ហើយមែនទេ? សូមស្តាប់ម្តងទៀត ហើយពិនិត្យមើលបណ្តើរ ថាតាមបណ្តើរ។

정답
1. (1) 까 (2) 뽀 (3) 쑤 (4) 찌
2. (1) 가요 (2) 짜요 (3) 커요 (4) 싸요 (5) 뿌리 (6) 아파요
4. (1) 꼬리 (2) 토끼 (3) 짜다 (4) 뿌리 (5) 어깨 (6) 쓰다

## 7 받침 ផាត់ឈីម(ព្យញ្ជនៈប្រកបខាងក្រោម)

K-7

ចំពោះភាសាខ្មែរ គឺធ្វើការសរសេរសម្រាយដេញពីឆ្វេងទៅស្តាំដូចជាភាសាអង់គ្លេសយ៉ាងអញ្ចឹង។ ក៏ប៉ុន្តែក្នុងភាសាកូរ៉េវិញ ករណីដែលព្យញ្ជនៈនៅពីក្រោយស្រៈ ដូចជាពាក្យ '공, 밥' គឺគេធ្វើការសរសេរព្យញ្ជនៈនៅពីក្រោមស្រៈ។ អាស្រ័យហេតុនេះ ព្យញ្ជនៈដែលត្រូវបានគេសរសេរនៅខាងក្រោមស្រៈ ត្រូវបានគេហៅថា'ផាត់ឈីម'។

공 밥

ផាត់ឈីម(ព្យញ្ជនៈប្រកបខាងក្រោម)

ជាធម្មតា ផាត់ឈីម គឺសុទ្ធសឹងតែជាព្យញ្ជនៈ តែក្នុងចំណោមព្យញ្ជនៈទាំង១៩ គឺមានព្យញ្ជនៈ៣(ㄸ, ㅃ, ㅉ) ដែលមិនអាចប្តូរខ្លួនជាផាត់ឈីមបាន។ ហើយចំពោះផាត់ឈីម គឺមានតែព្យញ្ជនៈទាំង៧នេះ(ㄱ, ㄴ, ㄷ, ㄹ, ㅁ, ㅂ, ㅇ)តែប៉ុណ្ណោះដែលមានសម្លេង។

| តួអក្សរ | សម្លេង | ឧទាហរណ៍ |
|---|---|---|
| ㄴ | [n] | 안: [안] |
| ㅁ | [m] | 암: [암] |
| ㅇ | [ŋ] | 앙: [앙] |
| ㄹ | [l] | 알: [알] |
| ㅂ, ㅍ | [p] | 압, 앞: [압] |
| ㄱ, ㄲ, ㅋ | [k] | 악, 앆, 앜: [악] |
| ㄷ, ㅌ, ㅅ, ㅆ, ㅈ, ㅊ, ㅎ | [t] | 앋, 앝, 앗, 았, 앚, 앛, 앟: [앋] |



បើអញ្ចឹង តោះយើងសាកល្បងអនុវត្តការបញ្ចេញសម្លេង ផាត់ឈីម ទាំងអស់គ្នា។
សូមស្តាប់ដោយប្រុងប្រយ័ត្ន ហើយថាតាម។

| | | | | | | |
|---|---|---|---|---|---|---|
| 나 [na] | 마 [ma] | x | 라 [ra] | 바 [pa] | 가 [ka] | 다 [ta] |
| 은 [ɨn] | 음 [ɨm] | 응 [ɨŋ] | 을 [ɨl] | 읍 [ɨp] | 윽 [ɨk] | 읃 [ɨt] |



តើយ៉ាងម៉េចដែរ? ពិបាកដែរឬទេ?

អ្នកបានដឹងហើយគឺមានពាក្យមួយថា 'ម្ប(បាយ)'។ កំណើតសម្លេងនៃព្យញ្ជនៈ 'ម' គឺជាប្រភេទតួអក្សរដែលបញ្ចេញសម្លេងចេញពីសួត ហើយវាខិតទៅរក 'ㅂ' ដែលខ្យល់ពីសួត ចេញមកខាងក្រៅ។ ក៏ប៉ុន្តែនៅពេលដែល 'ម' ដើរតួជា ផាត់ឈីម គឺវាងាកខិតទៅរក 'ឱ' ដែលជាសម្លេងបំបិទខ្យល់ពីសួត គឺវាមិនមានខ្យល់ចេញពីបបូរមាត់មកខាងក្រៅនោះទេ។



សូមស្តាប់ដោយប្រុងប្រយ័ត្នម្តងទៀត ហើយចូរថាតាមការបញ្ចេញសម្លេង។

តោះ! ពីពេលនេះទៅ យើងសាកល្បងសរសេរស្រៈ និងផាត់ឈីម លាយបញ្ចូលគ្នា។ សម្រាប់ផាត់ឈីម មិនថាវាសរសេរជាមួយនឹងស្រៈបញ្ឈរក៏ដោយ ស្រៈផ្តេកក៏ដោយ គឺវាត្រូវបានកំណត់ឲ្យសរសេរនៅខាងក្រោមនៃព្យាង្គ។ ជាដំបូង សូមសាកល្បងយកផាត់ឈីមមកសរសេរនៅពីក្រោមព្យាង្គដែលមានតែស្រៈបញ្ឈរ តែគ្មានព្យញ្ជនៈ ។

| CV | 이 | 아 |
|---|---|---|
| C | ㅂ | ㄴ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 아 + ㄴ | 안 | | | | | | |
| 야 + ㅁ | 얌 | | | | | | |
| 어 + ㅇ | 엉 | | | | | | |
| 여 + ㅂ | 엽 | | | | | | |
| 이 + ㄱ | 익 | | | | | | |



តើសរសេររួចរាល់ហើយមែនដែរឬទេ? សូមស្តាប់ CD ហើយសាកល្បងបញ្ចេញសម្លេងទៅតាមលំដាប់លំដោយ។



ចាស! ម្តងនេះ យើងសាកល្បងសរសេរផាត់ឈីមនៅពីក្រោមព្យាង្គដែលមានតែស្រៈបញ្ឈរ តែគ្មានព្យញ្ជនៈម្តង ។

| C<br>V | 요 | 우 |
|---|---|---|
| C | ㅇ | ㄴ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| 오 + ㄱ | 옥 | | | | | | | |
| 요 + ㅁ | 욤 | | | | | | | |
| 우 + ㅇ | 웅 | | | | | | | |
| 유 + ㄴ | 윤 | | | | | | | |
| 으 + ㅂ | 읍 | | | | | | | |



តើអ្នកបានសរសេររួចរាល់ហើយមែនដែរឬទេ? ម្តងនេះក៏ដូចមុនៗដែរ សូមស្តាប់ CD ហើយសាកល្បងបញ្ចេញសម្លេងទៅតាមលំដាប់លំដោយ។



ម្តងនេះ យើងមកសាកល្បងអនុវត្តសរសេរ ផាត់ឈីម នៅខាងក្រោមព្យាង្គដែលកើតចេញពីការបញ្ចូលនៃព្យញ្ជនៈដើមនិងស្រៈបញ្ឈរ។

| | | | | |
|---|---|---|---|---|
| CV | ㅅ | ㅏ | ㅈ | ㅣ |
| C | ㄴ | | ㅂ | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ㅅ + ㅏ + ㄴ | 산 | | | | | | | |
| ㅈ + ㅣ + ㅂ | 집 | | | | | | | |
| ㅂ + ㅏ + ㅁ | 밤 | | | | | | | |
| ㄴ + ㅓ + ㅁ | 넘 | | | | | | | |
| ㄱ + ㅕ + ㅇ | 경 | | | | | | | |



ម្តងនេះ យើងសាកអនុវត្តសរសេរ ផាត់ឈីម នៅខាងក្រោមព្យាង្គដែលកើតចេញពីការបញ្ចូលនៃព្យញ្ជនៈដើមនិងស្រៈផ្តេកម្តង។

| | | |
|---|---|---|
| C | ㄱ | ㅁ |
| V | ㅗ | ㅜ |
| C | ㅁ | ㄹ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ㄱ + ㅗ + ㅁ | 곰 | | | | | | |
| ㅁ + ㅜ + ㄹ | 물 | | | | | | |
| ㄱ + ㅜ + ㄱ | 국 | | | | | | |
| ㅈ + ㅡ + ㅂ | 즙 | | | | | | |
| ㅂ + ㅗ + ㄴ | 본 | | | | | | |



តើសរសេររួចរាល់ហើយមែនដែរឬទេ? សូមស្តាប់ CD ហើយចូរសាកល្បងបញ្ចេញសម្លេងទៅតាមលំដាប់លំដោយ។

អាចមានករណីនៅត្រង់ ផាត់ឈីម មានព្យញ្ជនៈដល់ទៅ ២។ ក៏ប៉ុន្តែក្នុងករណីបែបនេះ យើងធ្វើការបញ្ចេញសម្លេងតែមួយ ក្នុងចំណោមព្យញ្ជនៈទាំងពីរ។

값
[kap]



បើអញ្ចឹង តោះ! យើងសាកល្បងធ្វើការបញ្ចេញសម្លេងពាក្យខាងក្រោម។
សូមស្តាប់CDបណ្តើរ ថាតាមលំដាប់លំដោយបណ្តើរ។

| | | |
|---|---|---|
| 여덟 [yʌdʌl] | 닭 [tak] | 몫 [mok] |

| | | | | |
|---|---|---|---|---|
| 삶다 [samt´a] | 앉다 [ant´a] | 넓다 [nʌlt´a] | 맑다 [makt'a] | 젊다 [ʧʌmt'a] |



យ៉ាងម៉េចដែរ? ពិបាកទេ? សូមថាតាមម្តងទៀត ដោយប្រុងប្រយ័ត្នទៅលើការបញ្ចេញសម្លេង។

## 연습 ការអនុវត្ត

1. សូមស្តាប់ ហើយជ្រើសរើសចម្លើយដែលត្រឹមត្រូវ។

(1) 곰 공　　(2) 달 답　　(3) 목 몸
(4) 방 발　　(5) 삼 산　　(6) 일 입

2. សូមស្តាប់ ហើយថាតាម។

(1) 눈 산 편지　　(2) 밤 마음 몸무게
(3) 공 양 강아지　　(4) 달 딸 일
(5) 집 잎 수업　　(6) 국 밖 부엌
(7) 옷 낮 꽃　　(8) 책 붓 아홉

3. សូមស្តាប់ ហើយធ្វើការគូសសញ្ញា 'O' ទៅលើព្យញ្ជនៈដែលអ្នកបានស្តាប់លឺ។

(1) 닭 (ㄹ, ㄱ)　　(2) 몫 (ㄱ, ㅅ)　　(3) 값 (ㅂ, ㅅ)
(4) 앉다 (ㄴ, ㅈ)　　(5) 삶 (ㄹ, ㅁ)　　(6) 넓다 (ㄹ, ㅂ)

4. សូមស្តាប់ដោយប្រុងប្រយ័ត្ន ហើយសូមសរសេរអ្វីដែលអ្នកបានស្តាប់លឺជាអក្សរកូរ៉េ។

| | | | | |
|---|---|---|---|---|
| (1)  | | | | |
| (2)  | | | | |
| (3)  | | | | |
| (4)  | | | | |

| | | | | | |
|---|---|---|---|---|---|
| (5) | 1 | | | | |
| (6) |  | | | | |
| (7) |  | | | | |
| (8) |  | | | | |
| (9) |  | | | | |
| (10) |  | | | | |
| (11) |  | | | | |
| (12) |  | | | | |
| (13) |  | | | | |
| (14) | 3 | | | | |

정답 1. (1) 곰 (2) 달 (3) 목 (4) 방 (5) 산 (6) 입
3. (1) ㄱ (2) ㄱ (3) ㅂ (4) ㄴ (5) ㅁ (6) ㄹ
4. (1) 옷 (2) 양 (3) 집 (4) 입 (5) 일 (6) 잎 (7) 책 (8) 밖 (9) 구름 (10) 산 (11) 꽃 (12) 별 (13) 말 (14) 삼



តើអ្នកបានសរសេររួចរាល់ហើយមែនទេ? បន្ទាប់មកនេះ សូមធ្វើការបញ្ចេញសម្លេងបណ្តើរ ហើយសរសេរឲ្យបាន៣ដងថែមទៀតបណ្តើរ។

## 8 이어 읽기 ការអានបន្ត

K-8

ប្រសិនបើ នៅពីក្រោយផាត់ឈើម មានស្រៈ យើងត្រូវធ្វើការបញ្ចេញសម្លេងដោយយកព្យាង្គចុងក្រោយនៃផាត់ឈើម មកបញ្ចេញសម្លេងជាសម្លេងទីមួយ។

| | |
|---|---|
| 밥 을 → 밥 을 | [바블] |
| 먹 어 요 → 먹 어 요 | [머거요] |



សូមស្តាប់CD ហើយសាកល្បងថាតាម។ ប្រសិនបើនៅ ផាត់ឈើម មានព្យញ្ជនៈដល់ទៅ២ ព្យញ្ជនៈដែលនៅមុខគេ គឺយកមកបញ្ចេញសម្លេងជាមួយព្យាង្គមុខគេ ហើយព្យញ្ជនៈដែលនៅខាងក្រោយ គឺយកមកបញ្ចេញសម្លេងជាមួយព្យាង្គខាងក្រោយ។ បើ ផាត់ឈើម គឺជា‘ㄹ’ គឺវាអាចបញ្ចេញសម្លេងជា [r]បាន។

| | | |
|---|---|---|
| 음악[으막] | 한국어[한구거] | 할아버지[하라버지] |
| 집에[지베] | 꽃이[꼬치] | 이름이[이르미] |
| 걸어요[거러요] | 앉아요[안자요] | 읽어요[일거요] |



សូមសាកល្បងអានតែម្នាក់ឯងម្តងទៀត។ សូមស្តាប់ ហើយត្រួតពិនិត្យ។

### 연습 ការអនុវត្ត

1. សូមអានតួអក្សរខាងក្រោម។

(1) 물이 (2) 문을 (3) 앞에
(4) 닫아요 (5) 싫어요 (6) 있어요
(7) 깎아요 (8) 읽어요 (9) 앉아요

2. សូមអានល្បះខាងក្រោម។

(1) 창문을 닫으세요. (2) 사진을 찍었어요.
(3) 책에 이름을 쓰세요. (4) 물을 마시고 싶어요.
(5) 아침에 병원에 갔어요.



ចូរអនុវត្តការសរសេរព្យាង្គខាងក្រោម។

| ស្រៈ / ព្យញ្ជនៈ | ㅏ | ㅣ | ㅜ | ㅔ | ㅗ | ㅐ | ㅓ | ㅡ |
|---|---|---|---|---|---|---|---|---|
| ㄱ | 가 | | | | | | | |
| ㄴ | | 니 | | | | | | |
| ㄷ | | | 두 | | | | | |
| ㄹ | | | | 레 | | | | |
| ㅁ | | | | | 모 | | | |
| ㅂ | | | | | | 배 | | |
| ㅅ | | | | | | | 서 | |
| ㅇ | | | | | | | | 으 |
| ㅈ | | | | | | | | |
| ㅊ | | | | | | | | |
| ㅋ | | | | | | | | |
| ㅌ | | | | | | | | |
| ㅍ | | | | | | | | |
| ㅎ | | | | | | | | |
| ㄲ | | | | | | | | |
| ㄸ | | | | | | | | |
| ㅃ | | | | | | | | |
| ㅆ | | | | | | | | |
| ㅉ | | | | | | | | |